ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៣៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការទទួលស្គាល់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ឆ្នាំ២០២៥

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦.នស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ



ម

- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ស្ដីពីការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្ដល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្ដីពីការគ្រប់គ្រងថវិកា និងគណនេយ្យភាពសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានគណៈកម្មការវាយតម្លៃអង្គភាពផ្ដល់សេវាសាធារណៈថ្នាក់ជាតិ

**សម្រេច**

**មាត្រា១ .-**

ត្រូវបានទទួលស្គាល់ជ័យលាភីអង្គភាពផ្ដល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាលប្រចាំឆ្នាំ២០២៥ តាមលំដាប់ចំណាត់ថ្នាក់ ដូចខាងក្រោម៖

**១. វិស័យអប់រំ**

**១.១ អនុវិទ្យាល័យ**

| អង្គភាព | រាជធានី ខេត្ត | ចំណាត់ថ្នាក់ |
|---|---|---|
| អនុវិទ្យាល័យ មិត្តភាពខ្មែរ-ជប៉ុន ព្រះឥន្ទកោសា | សៀមរាប | លេខ១ |
| អនុវិទ្យាល័យ បាក់អំរែក | បាត់ដំបង | លេខ២ |
| អនុវិទ្យាល័យ ភ្នំយ៉ាត | ប៉ៃលិន | លេខ៣ |
| អនុវិទ្យាល័យ សម្ដេចឪ | ព្រះសីហនុ | លេខ៤ |
| អនុវិទ្យាល័យ ឈូកខ្សាច់ | កំពង់ធំ | លេខ៥ |
| អនុវិទ្យាល័យ សង្គមថ្មី | ព្រះវិហារ | លេខ៦ |
| អនុវិទ្យាល័យ ទួលថ្ម | កំពង់ចាម | លេខ៧ |
| អនុវិទ្យាល័យ អន្លង់អក | កំពង់ចាម | លេខ៨ |
| អនុវិទ្យាល័យ អរញ្ញរង្សី | សៀមរាប | លេខ៩ |
| អនុវិទ្យាល័យ បរកែវ | រតនគិរី | លេខ១០ |

**១.២ សាលាបឋមសិក្សា**

| អង្គភាព | រាជធានី ខេត្ត | ចំណាត់ថ្នាក់ |
|---|---|---|
| សាលាបឋមសិក្សា ហ៊ុន សែន មិត្តភាព | ព្រះសីហនុ | លេខ១ |
| សាលាបឋមសិក្សា ស្វាយជ្រំ | ស្វាយរៀង | លេខ២ |
| សាលាបឋមសិក្សា សម្ដេច ជា ស៊ីម | បាត់ដំបង | លេខ៣ |
| សាលាបឋមសិក្សា ក្រវ៉ាន់ | សៀមរាប | លេខ៤ |
| សាលាបឋមសិក្សា ថ្លុកជ្រៅ | កំពង់ចាម | លេខ៥ |
| សាលាបឋមសិក្សា ពោធិ៍សាត់ | ពោធិ៍សាត់ | លេខ៦ |
| សាលាបឋមសិក្សា គិរីសុវណ្ណវង្ស | កំពង់ឆ្នាំង | លេខ៧ |
| សាលាបឋមសិក្សា អនុវត្ត ហ៊ុន សែន អាចារ្យលាក់ | កំពង់ធំ | លេខ៨ |



9

| | | |
|---|---|---|
| សាលាបឋមសិក្សា អង្គជុំ | កំពត | លេខ៩ |
| សាលាបឋមសិក្សា ចតុមុខ | ភ្នំពេញ | លេខ១០ |

## ២. វិស័យសុខាភិបាល (មណ្ឌលសុខភាព)

| អង្គភាព | រាជធានី ខេត្ត | ចំណាត់ថ្នាក់ |
|---|---|---|
| មណ្ឌលសុខភាព គោកចក | សៀមរាប | លេខ១ |
| មណ្ឌលសុខភាព សំរោង | ពោធិ៍សាត់ | លេខ២ |
| មណ្ឌលសុខភាព ព្រៃញ្ញៅ | ព្រៃវែង | លេខ៣ |
| មណ្ឌលសុខភាព ស្រែណូយ | សៀមរាប | លេខ៤ |
| មណ្ឌលសុខភាព មិត្តភាពកម្ពុជា-កូរ៉េ ឈើទាល | ស្វាយរៀង | លេខ៥ |
| មណ្ឌលសុខភាព បឹងបត់កណ្ដោល | ពោធិ៍សាត់ | លេខ៦ |
| មណ្ឌលសុខភាព ពេជចង្វារ | កំពង់ឆ្នាំង | លេខ៧ |
| មណ្ឌលសុខភាព ស្វាយជុក | កំពង់ឆ្នាំង | លេខ៨ |
| មណ្ឌលសុខភាព បាសាក់ | ស្វាយរៀង | លេខ៩ |
| មណ្ឌលសុខភាព អង្គភ្នំតូច | កំពត | លេខ១០ |

**មាត្រា២ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ១៥កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ